# សេចក្តីថ្លែងការណ៍រួម
# ទម្លាក់ចោលអនុក្រឹត្យស្តីពីការបង្កើតច្រកអ៊ិនធឺណិតដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សតាមបណ្តាញអ៊ិនធឺណិតនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈឆ្នាំ ២០២១

យើងខ្ញុំជាអង្គការសង្គមស៊ីវិលជាតិអន្តរជាតិនិងសហគមន៍ ដែលមានឈ្មោះដូចខាងក្រោមសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យទម្លាក់ចោលអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិ("អនុក្រឹត្យ")។ អនុក្រឹត្យនេះបានបំពានកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាដោយបំពានមកលើសិទ្ធិតាមបណ្តាញអ៊ីនធើណិត និងក្រៅប្រព័ន្ធអ៊ីនធើណិតនៅកម្ពុជា ជាពិសេសសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាននិងសិទ្ធិឯកជនភាព។

អនុក្រឹត្យនេះ កំណត់ការបង្កើតនិងគ្រប់គ្រងច្រកទ្វារអ៊ិនធឺណិតថ្នាក់ជាតិ ដែលជាហេដ្ឋារចនាសម្ព័ន្ធតម្រូវអោយមានការប្រាស្រ័យទាក់ទងតាមអ៊ិនធឺណិតនិងចរាចរទិន្នន័យអ៊ិនធឺណិត ទាំងនៅខាងក្នុងនិងការចូលមកប្រទេសកម្ពុជា ដោយត្រូវឆ្លងកាត់ច្រកផ្លូវទ្វារអ៊ិនធឺណិតថ្នាក់ជាតិ។ អនុក្រឹត្យនេះសម្របសម្រួលឱ្យមានការឃ្លាំមើល និងតាមដានសកម្មភាពតាមអ៊ិនធឺណិត ផ្តល់សិទ្ធិអំណាចដល់ការតាមដាន និងការត្រួតពិនិត្យការប្រាស្រ័យទាក់ទងតាមប្រព័ន្ធឌីជីថល និងជួយដល់ការប្រមូល រក្សាទុក និងចែករំលែកទិន្នន័យផ្ទាល់ខ្លួន ដែលជាមូលដ្ឋាននាំឱ្យមានការគំរាមកំហែងដល់សិទ្ធិឯកជនភាព សេរីភាពខាងការបញ្ចេញមតិ និងទទួលព័ត៌មាន។ អនុក្រឹត្យនេះ មានគោលបំណងដាក់ឲ្យចរាចរអ៊ិនធឺណិតអន្តរជាតិទាំងអស់នៅក្រោមអំណាចអាជ្ញាធរតែមួយ ដែលធ្វើឱ្យរដ្ឋាភិបាលកាត់បន្ថយសកម្មភាពអ៊ិនធឺណិតក្នុងប្រទេសដែលមកពីអន្តរជាតិប្រកបដោយប្រសិទ្ធភាពថែមទៀត។

បន្ថែមលើការព្រួយបារម្ភអំពីបញ្ហាសិទ្ធិមនុស្សជាច្រើនដែលមានចែងក្នុងអនុក្រឹត្យនេះ ក៏មានការបារម្ភផងដែរថាអនុក្រឹត្យនេះនឹងផ្តល់លទ្ធភាពជាក់ស្តែង ជាពិសេសការបង្កើតហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់សម្រាប់ច្រកទ្វារអ៊ិនធឺណិតជាតិនេះ។ ការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិនេះទំនងជាបណ្តាលឱ្យមានការកាត់បន្ថយល្បឿនអ៊ីនធឺណិតដែលប្រការនេះបានបង្អាក់ការប៉ុនប៉ងរបស់រដ្ឋាភិបាលផ្សេងទៀត ក្នុងការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិដូចជាសំណើរបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិរបស់ប្រទេសថៃដែលត្រូវបានលុបចោលនៅឆ្នាំ២០១៥។ ការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិ នឹងមានផលប៉ះពាល់សេដ្ឋកិច្ច ជាពិសេសនៅលើទីផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចដែលកំពុងរីកចម្រើននៅកម្ពុជា ហើយក៏ដើរតួជាឧបសគ្គដល់ក្រុមហ៊ុនបច្ចេកវិទ្យានិងបង្កើតភាពមិនច្បាស់លាស់ដែលអាចបណ្តាលឱ្យអាជីវកម្មចាកចេញពីទីផ្សារប្រទេសកម្ពុជាផងដែរ។ ប្រសិនបើក្រុមហ៊ុនឯកជនត្រូវបានបង្ខំឱ្យចាកចេញទីបំផុតគឺអតិថិជនដែលជាបង់ថ្លៃសេវាយ៉ាងខ្ពស់។

ការព្រួយបារម្ភសំខាន់ៗរបស់យើងអំពីអនុក្រឹត្យនេះរួមមាន៖

**១. ការឃ្លាំមើល៖** អនុក្រឹត្យនេះ មានបំណងស្វែងរកការបង្កើតហេដ្ឋារចនាសម្ព័ន្ធដែលជួយសម្រួលដល់ការឃ្លាំមើលមួយដែលមានវិសាលភាពទូលំទូលាយមកលើសកម្មភាពតាមអ៊ិនធឺណិតនិងទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ម្នាក់ៗ។ ភាពមិនជាក់លាក់ដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះនឹងធ្វើឱ្យមានប្រព័ន្ធមួយដែលមានសមត្ថភាពអាចឃ្លាំមើលជាអតិបរមាជាមួយនឹងការត្រួតពិនិត្យអប្បបរមា ដែលនាំឱ្យជួយពង្រឹងអំណាចឃ្លាំមើលដោយមិនមានព្រំដែនស្រាប់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរំលោភសិទ្ធិឯកជនភាព។ សិទ្ធិឯកជនភាពដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ គឺជាសិទ្ធិជាមូលដ្ឋានរបស់មនុស្សដែលកំពុងរងការគំរាមកំហែងកាន់តែខ្លាំងឡើងៗដោយសារការឃ្លាំមើលតាមប្រព័ន្ធឌីជីថល។ ការរឹតត្បិតទៅលើសិទ្ធិទទួលបានឯកជនភាពគួរតែគោរពតាមគោលការណ៍នៃភាពស្របច្បាប់ សមាមាត្រនិងភាពចាំបាច់ រួមទាំងការបង្កើតប្រព័ន្ធការពារប្រព័ន្ធត្រួតពិនិត្យនិងការដោះស្រាយចំពោះការរំលោភបំពាន។ អនុក្រឹត្យនេះដែលផ្តល់សិទ្ធិត្រួតពិនិត្យសម្រាប់អង្គភាពរដ្ឋប៉ុណ្ណោះ ដែលនឹងមិនមានប្រសិទ្ធិភាពដល់ការគាំពារនិងជួយតាមដានលើការអនុវត្តប្រកបដោយប្រសិទ្ធិភាពនោះទេ។ នីតិវិធីការពារផ្ទៃក្នុងគ្មានប្រព័ន្ធត្រួតពិនិត្យរឹងមាំនិងឯករាជ្យ បង្ហាញថាគ្មានប្រសិទ្ធភាពប្រឆាំងនឹងការជ្រៀតជ្រែកឯកជនភាពដោយខុសច្បាប់ ឬដោយបំពាន ជាពិសេសតាមរយៈការឃ្លាំមើលក្នុងប្រព័ន្ធឌីជីថល។

បន្ថែមពីលើការរំលោភលើសិទ្ធិឯកជនភាព ការឃ្លាំមើលរបស់រដ្ឋាភិបាលបានបង្កើតបរិយាកាសនៃការភ័យខ្លាច បង្កើតការលើកទឹកចិត្តបន្ថែមទៀតសម្រាប់ការដាក់កំហិតនិងចាប់ពិរុទ្ធខ្លួនឯង ព្រមទាំងធ្វើឱ្យមានផលប៉ះពាលជាអវិជ្ជមានដល់សមត្ថភាពរបស់អ្នកសារព័ត៌មាននិងអ្នកការពារសិទ្ធិមនុស្សក្នុងការបំពេញការងាររបស់ខ្លួនផងដែរ។ ដូច្នេះការគំរាមកំហែងដោយសារការឃ្លាំមើល បានរារាំងដល់សិទ្ធិដែលត្រូវបានការពារមួយចំនួនទៀត រួមមានសេរីភាពក្នុងការបញ្ចេញមតិនិងសិទ្ធិទទួលបានព័ត៌មាន។

**២. ការត្រួតពិនិត្យ៖** មាត្រា ៦ នៃអនុក្រឹត្យនេះ ផ្តល់សិទ្ធិអំណាចឱ្យទប់ស្កាត់ ការតភ្ជាប់បណ្តាញ ឬខ្លឹមសារណាដែលចាត់ទុកថា«ប៉ះពាល់ដល់ចំណូលជាតិ សុវត្ថិភាព របៀបរៀបរយសណ្តាប់ធ្នាប់សង្គម សីលធម៌ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់»។ ការមិនបានកំណត់ឱ្យជាក់លាក់នូវមូលហេតុសម្រាប់ត្រួតពិនិត្យខ្លឹមសារ ផ្តល់អំណាចទូលំទូលាយដល់រដ្ឋាភិបាលក្នុងតាមដាន និងត្រួតពិនិត្យខ្លឹមសារតាមអ៊ិនធឺណិតដោយអនុក្រឹតស្តីពីការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិ នេះផ្តល់នូវសិទ្ធិក្នុងការចូលមើល និងត្រួតត្រារាល់ដំណើរការផ្លាស់ប្តូរទិន្នន័យនៅក្នុងប្រទេស។ បទបញ្ញត្តិនេះផ្ទុយពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដូចមានចែងក្នុងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៩ នៃ ក.ស.អ.ស.ព.ន ព្រោះវាហួសពីការរឹតត្បឹតដែលអាចធ្វើទៅបានចំពោះសេរីភាពខាងការបញ្ចេញមតិ។ បន្ថែមពីនោះទៅទៀត ការចែងមិនច្បាស់លាស់ត្រង់មាត្រា៦ ថាតើគេអាចរារាំងខ្លឹមសារណាមួយមុនការបោះពុម្ពផ្សាយ (ជាទម្រង់មួយនៃការត្រួតពិនិត្យជាមុន)ដែរឬទេ ដែលអាចជាការរឹតត្បិតយ៉ាងធ្ងន់ធ្ងរទៅលើសេរីភាពនៃការបញ្ចេញមតិ។

ការផ្ដល់សិទ្ធិអំណាចត្រួតពិនិត្យនៅក្នុងអនុក្រឹត្យនេះគឺជាហានិភ័យដ៏ធ្ងន់ធ្ងរ ដែលគេអាចប្រើប្រាស់អនុក្រឹត្យដើម្បីបិទ ឬដាក់ទណ្ឌកម្មលើមតិជំទាស់តាមបណ្ដាញអ៊ិនធឺណិត ដែលជាការរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការរិះគន់ និងការបញ្ចេញមតិផ្សេងទៀតដែលរដ្ឋាភិបាលកំណត់ថាមិនអាចទទួលយកបាន នឹងត្រូវបំបិទម្ដងហើយម្ដងទៀត ដាក់ទណ្ឌកម្ម និងដកហូតភាពស្របច្បាប់ ដែលបទដ្ឋានគតិយុត្តិថ្មីនេះនឹងត្រូវបានប្រើប្រាស់ដើម្បីហាមឃាត់ការរិះគន់ទៅលើរដ្ឋាភិបាល ស្ថាប័នរដ្ឋ និងអង្គភាពពាក់ព័ន្ធនឹងរដ្ឋផ្សេងទៀត ដោយរារាំងនូវគណនេយ្យភាព និងចូលរួមចំណែកឱ្យរដ្ឋាភិបាលបង្ក្រាបកាន់តែទូលំទូលាយទៅលើមតិជំទាស់។

**៣. ឯកជនភាពនៃទិន្នន័យៈ** មាត្រា ១៤ នៃអនុក្រឹត្យស្ដីនេះ បង្កហានិភ័យដល់ការការពារទិន្នន័យនិងការសម្ងាត់ទិន្នន័យដែលតម្រូវឱ្យមានការរក្សាទុកនិងចែករំលែកទិន្នន័យផ្ទាល់ខ្លួន។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិបញ្ញត្តិថាសិទ្ធិឯកជនភាពដែលមានចែងក្នុងមាត្រា ១៧ នៃ ក.ស.អ.ស.ព.ន រួមមានសិទ្ធិទទួលបានការការពារទិន្នន័យផ្ទាល់ខ្លួនក្នុងចំណោមសិទ្ធិដទៃទៀត ដែលរារាំងរដ្ឋពីការតម្រូវឱ្យក្រុមហ៊ុនរក្សាទុកទិន្នន័យផ្ទាល់ខ្លួនយ៉ាងច្រើន និងការចូលប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនខុសពីលក្ខខណ្ឌកំណត់ និងតម្រូវឱ្យការពារ។ អនុក្រឹត្យនេះ មិនបានបង្ហាញឱ្យបានជាក់លាក់នូវប្រភេទព័ត៌មាន ឬទិន្នន័យដែលអាចត្រូវរក្សាទុកនិងចែកចាយឡើយ ហើយជំនួសមកវិញដោយដាក់បញ្ចូលបញ្ញត្តិដែលមានភាពមិនច្បាស់លាស់ «ព័ត៌មានផ្សេងទៀតតាមតម្រូវការ» ដែលរដ្ឋាភិបាលអាចនឹងតម្រូវឱ្យក្រុមហ៊ុនផ្ដល់ការចូលមើលនូវទិន្នន័យផ្ទាល់ខ្លួនណាមួយតាមការចង់បាន។

លើសពីនេះទៀត តាមរយៈការតម្រូវឱ្យរក្សាទុកទិន្នន័យដោយមិនតម្រូវឱ្យមានការការពារគ្រប់គ្រាន់លើសន្តិសុខទិន្នន័យ អនុក្រឹត្យនេះបង្កើនហានិភ័យកាន់តែខ្លាំងដល់សន្តិសុខទិន្នន័យពីការជ្រៀតជ្រែកពីសំណាក់ភាគីទីបី ឬអ្នកលួចទិន្នន័យបច្ចេកវិទ្យាដទៃទៀត។ ការធ្វើមជ្ឈកម្មចរាចរអ៊ិនធឺណិត និងទិន្នន័យស្ថិតក្រោមច្រកទ្វារអ៊ិនធឺណិតជាតិបង្កើតចំណុចកណ្ដាលនៃភាពងាយរងគ្រោះសម្រាប់តួអង្គដែលរិះគន់ ខណៈពេលដែលតម្រូវការឱ្យមានការរក្សាទុកទិន្នន័យដោយមិនចាំបាច់ ជានានូវសមត្ថភាពរបស់អ្នកផ្ដល់សេវាកម្មដើម្បីដោះស្រាយឱ្យបានសមរម្យនូវការកើនឡើងនូវតម្រូវការសន្តិសុខទិន្នន័យធ្វើឱ្យមានហានិភ័យកាន់តែខ្ពស់ឡើងជុំវិញបញ្ហានេះ។

នាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្របខ័ណ្ឌច្បាប់ប្រទេសកម្ពុជា បានផ្ដល់អំណាចយ៉ាងលើសលប់ដល់រដ្ឋាភិបាលដើម្បីគ្រប់គ្រងសកម្មភាពនិងរឹតត្បិតលំហប្រជាធិបតេយ្យតាមប្រព័ន្ធអនឡាញ។ អ្វីដែលគួរឱ្យព្រួយបារម្ភនោះគឺការគំរាមកំហែងដោយអនុក្រឹត្យនេះ ចំពោះការបញ្ចេញមតិតាមរយៈបច្ចេកវិទ្យាឌីជីថលនិងសិទ្ធិឯកជនភាពត្រូវបានឡុកឡំដោយច្បាប់ដែលកើតឡើងផ្សេងទៀត គឺសេចក្ដីព្រាងច្បាប់ស្ដីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិត ដែលមានបទបញ្ញត្តិមួយចំនួនទូលំទូលាយ មិនត្រូវនឹងបទដ្ឋានអន្តរជាតិទាក់ទងទៅនឹងសេរីភាពខាងការបញ្ចេញមតិនិងសិទ្ធិឯកជនភាព។ អនុក្រឹត្យស្ដីពីការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិ ជាមួយនឹងច្បាប់ស្ដីពី

ទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងឆ្នាំ ២០១៨ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រនិងបណ្តាញសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ិនធឺណិតនៅព្រះរាជាណាចក្រកម្ពុជាផ្តល់អំណាចកាន់តែច្រើនឡើងៗដល់រដ្ឋាភិបាលដើម្បីប្រើប្រាស់អ៊ិនធឺណិតជាឧបករណ៍បង្ក្រាបនិងរារាំងដល់សក្តានុពលរបស់អ៊ីនធឺណិត ដែលជាវេទិកាដ៏សំខាន់សម្រាប់ការអនុវត្តសេរីភាពមូលដ្ឋាន។

យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល សូមទម្លាក់ចោលអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ិនធឺណិតជាតិស្របតាមកាតព្វកិច្ចរបស់កម្ពុជាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិដោយធានាថាសិទ្ធិសេរីភាពខាងការបញ្ចេញមតិនិងព័ត៌មាន និងសិទ្ធិឯកជនភាពរបស់បុគ្គលទាំងអស់នៅកម្ពុជាត្រូវបានការពារ។

--- ចប់---

**សេចក្តីថ្លែងការណ៍នេះ គាំទ្រដោយ៖**

1 អង្គការអាក់សិនអេដកម្ពុជា
2 វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
3 វេទិកាអាស៊ីដើម្បីសិទ្ធិមនុស្សនិងការអភិវឌ្ឍ (FORUM-ASIA)
4 សហគមន៍ដីធ្លីបឹងទន្លេម្រេច
5 សហគមន៍បឹងប្រាំ
6 សហគមន៍បឹងឈូក
7 អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
8 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
9 មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
10 សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា
11 អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា
12 សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា
13 សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ
14 អង្គការជនជាតិដើមភាគតិចកម្ពុជា
15 សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
16 មជ្ឈមណ្ឌលដើម្បីច្បាប់ និងប្រជាធិបតេយ្យ
17 សម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS)
18 សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម
19 អង្គការសមធម៌កម្ពុជា

20 សហគមន៍បណ្ដាញអតីតស្ត្រីបឹងកក់
21 អង្គការយេនឌ័រនិងអភិវឌ្ឍន៍នៅកម្ពុជា
22 អង្គការអោយហ្វិក
23 សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
24 សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្សនិងអភិវឌ្ឍន៍
25 អង្គការភ្លាហាន
26 សហគមន៍ដីធ្លីដីខក្រោម ភូមិព្រែកជីក ឃុំដីខក្រោម ខេត្តកោះកុង
27 សហគមន៍ដីធ្លីប៉ៃលិន ខេត្តប៉ៃលិន
28 សហគមន៍ដីធ្លីឡពាង(កំពង់ឆ្នាំង)
29 អង្គការមូលនិធិ Manushya
30 សហគមន៍ការពារធនធានធម្មជាតិស្រុកក្រគរ ខេត្តពោធិសាត់
31 បណ្ដាញអ្នកការពារព្រៃឡង់ ឃុំមានរិទ្ធិ ស្រុកសណ្ដាន់ (កំពង់ធំ)
32 គណៈកម្មាធិការអព្យាក្រិតនិងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវនៅកម្ពុជា
33 សហគមន៍ភ្នំបាត
34 សហគមន៍ព្រៃឈើភ្នំដែក ចំបក់ហោះ
35 សហគមន៍ភ្នំក្រោម ខេត្តសៀមរាប
36 សហគមន៍ភូមិ ២៣
37 អង្គការពន្លកខ្មែរ
38 សហគមន៍ព្រៃពាយ ខេត្តកំពត
39 សហគមន៍ព្រៃឈើរតនរុក្ខា ខេត្តឧត្តរមានជ័យ
40 សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ
41 សហគមន៍ភូមិតានី១៩៧ ខេត្តកោះកុង
42 សហគមន៍ទួលសង្កែ B
43 អង្គការតម្លាភាពកម្ពុជា
44 សហគមន៍ត្រពាំងសង្កែ ខេត្តកំពត
45 អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT)